00234900

**Declassified to Public**
**06 September 2012**

D99/3/26

នៅចំពោះមុខអង្គបុរេជំនុំជម្រះ
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 10 / 2008
ម៉ោង (Time/Heure): 14 : 10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA

| | |
|---|---|
| សំណុំរឿងលេខ: | ០០១/១៨-០៧-២០០៧-អ.វ.ត.ក-ក.ស.ច.ស(អ.ប.ជ.០២) |
| បញ្ជូនទៅ: | អង្គបុរេជំនុំជម្រះ |
| កាលបរិច្ឆេទនៃការបញ្ជូន | ថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៨ |
| ភាគីបញ្ជូន: | មេធាវីការពារអ្នកស្រី អៀង ធិរិទ្ធ លោក នួន ជា និង លោក ខៀវ សំផន |
| ភាសាដើម: | ខ្មែរ និង អង់គ្លេស (បកប្រែជាភាសាបារាំង) |
| ប្រភេទឯកសារ: | សាធារណៈ |

## សំណើរួមរបស់មេធាវីការពារ ស្នើសុំការចូលអន្តរាគមន៍នៅក្នុងការអនុវត្តទ្រឹស្តី JCE នៅក្នុង បណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ " ឌុច "

| បញ្ជូនដោយ៖ | អ្នកទទួលឯកសារ: |
|---|---|
| **សហមេធាវីការពារក្តីអ្នកស្រី អៀង ធីរិទ្ធ** | **ចៅក្រមអង្គបុរេជំនុំជម្រះ** |
| លោកមេធាវី ផាត់ ពៅស៊ាង | ប្រាក់ គឹមសាន |
| កញ្ញា Diana ELLIS QC | លោក ហួត វុទ្ធី |
| | លោក Rowan DOWNING |
| **សហមេធាវីការពារក្តីលោក នួន ជា** | លោក ន័យ ថុល |
| លោក សុន អរុណ | លោកស្រី Katinka LAHUIS |
| លោក Michiel PESTMAN | លោក ប៉ែន ពេជ្រសាលី |
| លោក Victor KOPPE | **សហព្រះរាជអាជ្ញា** |
| **សហមេធាវីការពារក្តីលោក ខៀវ សំផន** | លោកស្រី ជា លាង |
| លោក ស សូវ៉ាន | លោក Robert PETIT |
| លោក Jacques VERGÈS | **មេធាវីរបស់ដើមបណ្តឹងរដ្ឋប្បវេណី៖** |
| | លោកមេធាវី ហុង គឹមសួន |
| | លោកមេធាវី ឡោ ជុនធី |
| | លោកមេធាវី នី ចាន់ឌី |
| | លោកមេធាវី គង់ ពិសី |
| | Silke Studzinsky |
| | លោកមេធាវី យ៉ុង ផានីត |
| | Martine JACQUIN |

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 27 / 10 / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

## I. សេចក្តីផ្តើម

1. នៅថ្ងៃទី២១ ខែសីហា ឆ្នាំ២០០៨ ការិយាល័យសហព្រះរាជអាជ្ញា (ហៅថា "ក.ស.ព") បានដាក់សេចក្តីជូនដំណឹងស្តីពីបណ្តឹងឧទ្ធរណ៍ប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះរបស់សហចៅក្រមស៊ើបអង្កេត នៅក្នុងសំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អ.វ.ត.ក/ក.ស.ច.ស ។ នៅថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០០៨ ក.ស.ព បានដាក់សារណាបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញា (ហៅថា "បណ្តឹងឧទ្ធរណ៍របស់ ក.ស.ព") ស្នើសុំឱ្យអង្គបុរេជំនុំជម្រះ *ក្នុងចំណោមបញ្ហាដទៃទៀត* កែប្រែដីកាបញ្ជូនរឿងទៅជំនុំជម្រះ ដើម្បីដាក់បញ្ចូលទម្រង់នៃការចូលរួមជាសហកម្មឧក្រិដ្ឋកម្មរួម (ហៅថា "JCE") នៅក្នុងរឿងក្តីប្រឆាំង កាំង ហ្គេកអ៊ាវ (ហៅ "ឌុច") ។

2. នៅថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨ មេធាវីការពាររបស់ អៀង សារី បានដាក់ "សំណើជាបន្ទាន់ដើម្បីស្នើសុំដាក់អំណះអំណាងស្តីពីការអនុវត្តនូវការទទួលខុសត្រូវជាទម្រង់សហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះ លើករណីកាំង ហ្គេកអ៊ាវ (ហៅ"ឌុច") ។ អង្គបុរេជំនុំជម្រះបានបដិសេធបណ្តឹងឧទ្ធរណ៍នេះនៅក្នុង "សេចក្តីសម្រេចលើសំណើរបស់ អៀង សារី ស្នើសុំដាក់អំណះអំណាងស្តីពីការអនុវត្តនូវការទទួលខុសត្រូវជាទម្រង់សហកម្មឧក្រិដ្ឋកម្មរួម នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាជំទាស់ទៅនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី កាំង ហ្គេកអ៊ាវ ហៅ "ឌុច" (ហៅថា "សេចក្តីសម្រេចរបស់ អ.ប.ជ លើករណី អៀង សារី") ។

3. ជនត្រូវចោទដែលដាក់សារណានេះ រួមមាន អ្នកស្រី **អៀង ធីរិទ្ធ** លោក **នួន ជា** និង លោក **ខៀវ សំផន** (ហៅថា "**ជនត្រូវចោទ**") ត្រូវបានចោទប្រកាន់ ក្នុងចំណោមបញ្ហាដទៃទៀត ថាជាភាគីនៃសហកម្មឧក្រិដ្ឋកម្មរួម ដូចដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ[1] ។

4. មេធាវីការពារក្តីរបស់ជនត្រូវចោទស្នើសុំឱ្យអង្គបុរេជំនុំជម្រះ បើកសវនាការលើបណ្តឹងឧទ្ធរណ៍របស់ ក.ស.ព នៅក្នុងដំណើរការនីតិវិធីជាបន្ទាន់ ។

5. មូលហេតុដែលមេធាវីការពារក្តីស្វែងរកឱ្យមានសវនាការលើបណ្តឹងឧទ្ធរណ៍នេះ គឺថាខ្លួនមានផលប្រយោជន៍ដោយផ្ទាល់នៅក្នុងបញ្ហាដែលត្រូវសំអាង ហើយស្នើសុំឱ្យអង្គបុរេជំនុំជម្រះធ្វើសេចក្តីសម្រេច ។ រាល់សេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះទាក់ទងនឹងការអនុវត្តនៃ JCE នឹងប៉ះពាល់

---

[1] ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យទៅស៊ើបសួរ កថាខណ្ឌ ២, ៥ ដល់ ១៦ និង កថាខណ្ឌ ១១៦ ។

00234902



ដោយផ្ទាល់ទៅលើដំណើរការនីតិវិធីប្រឆាំងនឹងជនត្រូវចោទ ។ អាស្រ័យហេតុនេះ មេធាវីការពារក្តីសូមដាក់ "សំណើសុំចូលអន្តរាគមន៍នៅក្នុងការអនុវត្តទ្រឹស្តី JCE នៅក្នុងបណ្តឹងឧទ្ធរណ៍របស់ ក.ស.ព ប្រឆាំងនឹងដីកាសន្និដ្ឋានបញ្ជូនរឿងទៅជំនុំជម្រះលើករណី ឌុច" (ហៅថា"សំណើមេធាវីការពារក្តី")។

## II. បទដ្ឋានដែលអាចអនុវត្តបាន

6. នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនលើករណី អៀង សារី អង្គបុរេជំនុំជម្រះបានសន្និដ្ឋានថា "វិធានផ្ទៃក្នុងមិនបានចែងអំពីសិទ្ធិរបស់តតីយជនក្នុងការចូលអន្តរាគមន៍ទេ"[2] ។ ប៉ុន្តែ អង្គបុរេជំនុំជម្រះរំលឹកថា នៅក្នុងករណីប្រឆាំងនឹងលោក អៀង សារី ជនត្រូវចោទដទៃទៀតត្រូវបានអនុញ្ញាតឲ្យចែករំលែកទស្សនៈរបស់ពួកគេជាមួយអង្គបុរេជំនុំជម្រះនៅក្នុងសំណុំរឿងដាច់ដោយឡែក ពីព្រោះ "ការអញ្ជើញត្រូវបានធ្វើឡើង នៅក្នុងកាលៈទេសៈដែលថាការសម្រេចលើពាក្យសុំអាចនាំដល់ការចេញសេចក្តីបង្គាប់ជាទូទៅលើសិទ្ធិនីតិវិធីដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង ក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ"[3] ។

7. សិទ្ធិរបស់ជនត្រូវចោទដទៃទៀត ដើម្បីចូលអន្តរាគមន៍នៅក្នុងសំណុំរឿងប្រឆាំងជនត្រូវចោទម្នាក់ គឺត្រូវបានដាក់កម្រិតចំពោះតែករណីដែលសម្រេចអាចអនុវត្តក្រៅពីសំណុំរឿងរបស់ជនត្រូវចោទតែម្នាក់ឯង ។ មូលហេតុនេះត្រូវតែអនុវត្តស្មើៗគ្នាចំពោះសិទ្ធិជាសារវ័ន្តរបស់ជនត្រូវចោទដែលនឹងត្រូវប៉ះពាល់ដោយសេចក្តីសម្រេចបែបនេះ ។

8. ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចថា ជនត្រូវចោទពុំមានសិទ្ធិក្នុងការធ្វើអន្តរាគមន៍ទេ នោះមេធាវីការពារស្នើសុំដោយគោរពថា សំណើនេះត្រូវតែបានអនុញ្ញាតដោយមូលហេតុសេដ្ឋកិច្ចរបស់តុលាការ និងដើម្បីទទួលស្គាល់សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការកាត់សេចក្តីដោយត្រឹមត្រូវ និងយុត្តិធម៌ (ចំនុចនេះនឹងដោះស្រាយនៅផ្នែក ៣.៣ ខាងក្រោម) ។

## III. អំណះអំណាង

### ៣.១ បញ្ហា

[2] សាលដីការបស់ អ.ប.ជ លើករណី អៀង សារី កថាខណ្ឌ ៨ ។

[3] សាលដីការបស់ អ.ប.ជ លើករណី អៀង សារី កថាខណ្ឌ ១១ ។

9. មាត្រា ២៩ នៃច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា បានកំណត់ទម្រង់នៃការចូលរួមការប្រព្រឹត្តឧក្រិដ្ឋកម្មដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អ.វ.ត.ក ។ ច្បាប់នេះមិនបានយោងទៅលើ JCE នោះទេ ។ អាស្រ័យហេតុនេះ មានបញ្ហាមួយកើតឡើងថា តើតុលាការអាចសន្និដ្ឋានថា JCE មានលទ្ធភាពតំណាងឲ្យទម្រង់នៃការចូលរួមដែល អ.វ.ត.ក មានយុត្តាធិការដែរ ឬយ៉ាងណានោះ ។

10. សំខាន់ជាងនេះទៅទៀត ខណៈដែលក្រមព្រហ្មទណ្ឌកម្ពុជាមិនបានទទួលស្គាល់ជាប្រវត្តិសាស្ត្រនូវ JCE ថាជាទម្រង់នៃការចូលរួម ថាតើជនដែលត្រូវចោទប្រកាន់ពីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៧៩ អាចត្រូវរកឃើញថាត្រូវទទួលខុសត្រូវបានដែរឬទេ ដោយគ្រាន់តែជាភាគីនៃសហកម្មឧក្រិដ្ឋកម្មរួម ។ សំនួរនេះនឹងកាន់តែស្មុគស្មាញខ្លាំងថែមទៀតនៅពេលមានសំនួរថាតើទស្សនាទាននៃ JCE មានទម្រង់នៃការទទួលខុសត្រូវ ក្រោមច្បាប់ទំនៀមទំលាប់អន្តរជាតិ នៅក្នុងអម្លុងពេលពាក់ព័ន្ធពីឆ្នាំ១៩៧៥ ដល់ ១៩៧៩ ដែរ ឬ យ៉ាងណានោះ ។

## ៣.២ ការជាប់ពាក់ព័ន្ធដោយផ្ទាល់ជាមួយជនត្រូវចោទ

11. អង្គបុរេជំនុំជម្រះបានស្វែងរកជំនួយពីអ្នកដែលមិនមែនជាភាគីនៃរឿងក្តីចំនួនបី នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនថា តើ JCE អាចអនុវត្តបានចំពោះឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តនៅក្នុងអំឡុងពេលចន្លោះពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ដែរឬយ៉ាងណានោះ។

12. សេចក្តីសម្រេចទាំងឡាយដែលអង្គបុរេជំនុំជម្រះសម្រេចទៅលើបញ្ហានេះ គឺមានសារៈសំខាន់ដោយផ្ទាល់ចំពោះជនត្រូវចោទនៅក្នុងសំណុំរឿងលេខ ០០២ នៅពេលដែលអង្គបុរេជំនុំជម្រះបានសម្រេចទៅលើបញ្ហាដែលមានភាពមិនច្បាស់លាស់ស្តីពីការអនុវត្ត JCE ក្នុងអំឡុងពេលចន្លោះពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ ព្រោះអង្គបុរេជំនុំជម្រះមិនអាចកែប្រែការសម្រេចបែបនោះបានទេនៅថ្ងៃខាងមុខ។ អាចឲ្យជំទាស់តវ៉ាបានដែរ ការិយាល័យសហចៅក្រមស៊ើបអង្កេត (“ក.ស.ច.ស”) នៅក្នុងសំណុំរឿងលេខ ០០២ អាចកែប្រែសេចក្តីសម្រេចបែបនោះបាន ប៉ុន្តែ ដោយសារអង្គបុរេជំនុំជម្រះមានយុត្តាធិការខ្ពស់ជាង ក.ស.ច.ស និង បានបញ្ជាក់យ៉ាងច្បាស់ថា ខ្លួននឹងធ្វើការសម្រេចលើបញ្ហានេះទៅក្នុងករណីរបស់ អៀង សារី បន្ទាប់ពីអង្គបុរេជំនុំជម្រះបានសម្រេចសេចក្តីទៅលើបញ្ហានេះ។ គេរំពឹងថា ក.ស.ច.ស នឹងមិនងាកចេញឆ្ងាយពីទស្សនៈរបស់អង្គបុរេជំនុំជម្រះឡើយ។ ជាការពិត ប្រសិនបើមិនមានការយល់ព្រមជាមួយនឹងសេចក្តីសម្រេចនៅក្នុង

សំណុំរឿងលេខ ០០១ របស់អង្គបុរេជំនុំជម្រះទេ នោះវាមិនអាចជៀសផុតបានទេថា អង្គបុរេជំនុំជម្រះអាចកែប្រែសេចក្តីសម្រេចរបស់ខ្លួនតាមរយៈបណ្តឹងឧទ្ធរណ៍នេះ ។

13. លើសពីនេះទៅទៀត បញ្ហានេះក៏អាចលើកឡើងយ៉ាងច្បាស់ផងដែរនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងដែលអាចសម្រេចទៅលើចំនុចនេះជាថ្មីម្តងទៀត[4]។ ដើម្បីផលប្រយោជន៏ផ្នែកសេដ្ឋកិច្ចរបស់តុលាការ ភាពស៊ីសង្វាក់គ្នា និងប្រសិទ្ធភាព អាចនឹងមានការមិនពេញចិត្តក្នុងការកែប្រែសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះ។ សំខាន់ណាស់ដែរ គេអាចស្មានទុកជាមុនថា អង្គជំនុំជម្រះសាលាដំបូងនឹងដោះស្រាយបញ្ហានេះនៅក្នុងរឿងក្តីប្រឆាំងនឹង ឌុច ដែលរំពឹងថាស្ថានភាពដូចគ្នានេះត្រូវបានលើកឡើង ដែលក្នុងនោះ ប្រសិនបើមេធាវីការពារក្តីរបស់ជនត្រូវចោទផ្សេងទៀតមិនមែនជាភាគីចំពោះរឿងក្តីនោះ ពួកគេនឹងត្រូវបានដកចេញពីការពិភាក្សាដ៏សំខាន់នេះដែលពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងសំណុំរឿងរបស់ខ្លួន។

14. តាមការយល់ឃើញចំពោះរឿងក្តីនោះ ប្រសិនបើមេធាវីការពារក្តីរបស់ ឌុច មិនស្វែងរកការដាក់អំណះអំណាងលើបញ្ហានេះទេ នោះអង្គបុរេជំនុំជម្រះនឹងត្រូវបានដកហូតឱកាសដើម្បីដាក់ទម្ងន់ទៅលើទឡ្ហីករណ៍ទាំងឡាយ ដោយការពិចារណាទៅលើគោលជំហរដែលលើកឡើងដោយអ្នកដែលប៉ះពាល់ធ្ងន់ធ្ងរបំផុតដោយសេចក្តីសម្រេចភ្លាមៗរបស់ពួកគេ។

15. ភាពយុត្តិធម៌នៃដំណើរការនីតិវិធី គួរត្រូវបានសម្របសម្រួលដោយការខកខានរបស់អង្គបុរេជំនុំជម្រះក្នុងការអនុញ្ញាតឲ្យមេធាវីការពារដាក់ជូនទឡ្ហីករណ៍។ ចំនុចនេះអាចធ្វើឲ្យកើតមានឡើងនូវការមិនមានតុល្យភាពនៅក្នុងការដាក់ទឡ្ហីករណ៍ជូន ហើយដែលផ្ទុយទៅនឹងសិទ្ធិរបស់ជនត្រូវចោទក្នុងការ ទទួលបានការជំនុំជម្រះទៅលើបញ្ហាពាក់ព័ន្ធទាំងអស់។

16. ហេតុដូច្នេះ ការបដិសេធមិនឲ្យមេធាវីការពារក្តីដាក់អំណះអំណាងផ្នែកច្បាប់ទៅលើបញ្ហាដ៏សំខាន់នេះ អាចប៉ះពាល់យ៉ាងខ្លាំងដល់សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីដោយយុត្តិធម៌។ ហេតុដូច្នេះ មេធាវីការពារក្តីរបស់ជនត្រូវចោទ សូមលើកឡើងថា គួរអនុញ្ញាតឲ្យពួកគេចូលរួមនៅក្នុងការជំនុំជម្រះទៅលើបញ្ហាដ៏សំខាន់នេះដែលជាចំនុចស្នូលចំពោះការចោទប្រកាន់ដែលត្រូវប្រឈម ហើយដែលនឹងកំណត់ភ្លាមៗពីប្រភេទនៃការចោទប្រកាន់ដែលបានព្រាងឡើងប្រឆាំងមកលើជនត្រូវចោទ។

## ៣.៣ សេដ្ឋកិច្ចតុលាការ និង សិទ្ធិរបស់ជនត្រូវចោទ

[4] ទឡ្ហីករណ៍ដដែលនេះនឹងដាក់ជូនអង្គជំនុំជម្រះតុលាការកំពូល។

### សេដ្ឋកិច្ចតុលាការ

17. ទីមួយ មេធាវីការពារក្តីរបស់ជនត្រូវចោទសូមលើកឡើងថា ដើម្បីហេតុផលសេដ្ឋកិច្ចតុលាការ ពួកខ្លួនត្រូវតែបានអនុញ្ញាតឱ្យដាក់អំណះអំណាងទាំងឡាយ នៅក្នុងដំណាក់កាលនេះនៃដំណើរការនីតិវិធី ។ ប្រសិនបើអង្គបុរេជំនុំជម្រះមានគោលបំណងធ្វើសេចក្តីសម្រេចទៅលើទស្សនៈនៃ JCE និងការអនុវត្ត JCE នៅចន្លោះអំឡុងពេលពីឆ្នាំ ១៩៧៥ ដល់ ១៩៧៩ អង្គជំនុំជម្រះនេះត្រូវតែបានជូនដំណឹងនូវទឡ្ហីករណ៍ពាក់ព័ន្ធទាំងអស់។ ដើម្បីហេតុផលនេះ មេធាវីការពារក្តីសន្និដ្ឋានថា អង្គបុរេជំនុំជម្រះបានអញ្ជើញអ្នកមិនមែនជាភាគីនៃរឿងក្តី ដើម្បីជួយដល់ការចេញសេចក្តីសម្រេចមួយដែលប្រកបដោយព័ត៌មាន និងមូលហេតុគ្រប់គ្រាន់។ បច្ចុប្បន្ននេះ ព្រះរាជអាជ្ញា ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកមិនមែនជាភាគីនៃរឿងក្តី អាចចូលរួមក្នុងការពិភាក្សាដេញដោល ដោយមិនរាប់បញ្ចូលនូវមេធាវីការពារក្តីឡើយ។ ការមិនដាក់បញ្ចូលនូវអំណះអំណាងរបស់មេធាវីការពារក្តីបែបនេះអាចផ្តល់លទ្ធផលនៅក្នុងសេចក្តីសម្រេចរបស់អង្គបុរេជំនុំជម្រះដែលមិនបានទទួលដំណឹងមួយផ្នែកណាមួយ និងបានធ្វើឱ្យមានកំហុស ប្រសិនបើសម្រាប់តែហេតុផលនីតិវិធីតែប៉ុណ្ណោះ។

### ការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌: សិទ្ធិទទួលបានការជំនុំជម្រះ

18. ទីពីរ ការបដិសេធមិនឱ្យជនត្រូវចោទដាក់អំណះអំណាងទៅលើបញ្ហានេះនឹងរារាំងដល់សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះទៅលើបញ្ហាទាំងឡាយ ដែលមានការពាក់ព័ន្ធដោយផ្ទាល់ចំពោះរឿងក្តីរបស់ពួកគេ និងទៅលើបញ្ហាដែលត្រូវបានសម្រេចភ្លាមៗ។ ដូចដែលបានលើកឡើងពីមុនរួចមកហើយ ពុំមានសារណានៅចំពោះមុខ ក.ស.ច.ស ណានឹងទទួលបានជោគជ័យទេ ប្រសិនបើជនត្រូវចោទដាក់ជូននូវទស្សនៈផ្ទុយទៅនឹងសេចក្តីសម្រេចដែលបានកំណត់ឡើងដោយអង្គបុរេជំនុំជម្រះរួចមកហើយនោះ។

19. ចំនុចនេះអាចបញ្ជាក់ន័យថា សិទ្ធិរបស់ជនត្រូវចោទក្នុងការទទួលបានការជំនុំជម្រះក្តីដូចដែលមានចែងនៅក្នុងមាត្រា ១៤(១)នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងនយោបាយត្រូវបានរំលោភបំពាន[5]។ មេធាវីការពារក្តីនឹងបាត់បង់សិទ្ធិរបស់ខ្លួនក្នុងការទទួលបានការជំនុំជម្រះ ដោយប្រសិទ្ធភាពទៅលើបញ្ហាដ៏សខាន់នេះ។

---

[5] បទប្បញ្ញត្តិនេះ ត្រូវបានអនុវត្តយ៉ាងច្បាស់លាស់នៅក្នុងឬបព័ន្ធរបស់ អ.វ.ត.ក តាមរយៈមាត្រា ១៣ នៃ "កិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជាទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ" ដែលចែងថា "សិទ្ធិរបស់ជនត្រូវចោទដែលបានចែងនៅក្នុងមាត្រា

00234906

D99/3/26



**ការរំលោភសិទ្ធិប្តឹងឧទ្ធរណ៍**

20. លើសពីនេះទៅទៀត ជនត្រូវចោទមិនមែនត្រឹមតែត្រូវបានបដិសេធចំពោះសិទ្ធិទទួលបានការជំនុំជម្រះក្តីប៉ុណ្ណោះទេ ពួកគេក៏ពុំទទួលបាននូវការស្វែងរកភាពធូរស្រាលប្រកបដោយប្រសិទ្ធភាពនៅដំណាក់កាលប្តឹងឧទ្ធរណ៍នេះដែរ។ ដោយមានការជាប់ទាក់ទិនដូចមានលើកឡើងខាងលើ មេធាវីការពារក្តីរបស់ជនត្រូវចោទមិនបានចូលរួមពាក់ព័ន្ធនៅក្នុងការពិភាក្សាដេញដោលទេ ប្រហែលជានៅគ្រប់កម្រិតនៅចំពោះមុខអង្គជំនុំជម្រះនេះ។ សិទ្ធិរបស់ជនត្រូវចោទក្នុងការប្តឹងឧទ្ធរណ៍ជំទាស់ទៅនឹងបញ្ហានេះក៏ប្រហែលជាត្រូវបានបដិសេធដូចគ្នានេះដែរ។

21. បន្ថែមលើនេះទៅទៀត ពុំមានភាគីណាទទួលរងនូវព្យសនកម្មណាមួយនោះទេ ប្រសិនបើមេធាវីការពារក្តីរបស់ជនត្រូវចោទដាក់អំណះអំណាង តែជនត្រូវចោទអាចទទួលរងនូវព្យសនកម្មដោយសារការបដិសេធបែបនេះ។ បន្ថែមទៅលើអំណះអំណាងផ្នែកសេដ្ឋកិច្ចតុលាការ ក៏ដូចជាការរំលោភសិទ្ធិទទួលបានការជំនុំជម្រះដោយយុត្តិធម៌ មេធាវីការពារក្តីស្នើថា ព្យសនកម្មនេះអាចបញ្ចុះបញ្ចូលឲ្យអង្គបុរេជំនុំជម្រះអនុញ្ញាតឲ្យជនត្រូវចោទដាក់អំណះអំណាងទៅលើបញ្ហានេះ។

22. ប្រសិនបើអង្គបុរេជំនុំជម្រះអនុញ្ញាតឲ្យមេធាវីការពារជនត្រូវចោទដាក់អំណះអំណាង មេធាវីការពារក្តីសូមស្នើថា អំណះអំណាងនេះគួរតែធ្វើឡើងនៅក្នុងរង្វង់នៃពេលវេលាមួយដែលមិនបណ្តាលឲ្យមានការពន្យារពេលនៅក្នុងដំណើរនីតិវិធី ។

## IV. សំណូមពរ

23. ប្រសិនបើអង្គបុរេជំនុំជម្រះសម្រេចលើភាពអាចអនុវត្តបាននៃ JCE នៅពេលនេះ និង នៅដំណាក់កាលនៃដំណើរនីតិវិធីនៅក្នុងសំណុំរឿង ឌុច មេធាវីការពារក្តីជនត្រូវចោទស្នើសុំការអនុញ្ញាតដើម្បីធ្វើអន្តរាគមន៍នៅក្នុងបណ្តឹងឧទ្ធរណ៍របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងដីកាបញ្ជូនរឿងទៅជំនុំជម្រះលើករណី ឌុច និងដាក់អំណះអំណាងលើបញ្ហានេះ ។

24. មេធាវីការពារក្តីស្នើដោយគោរពសុំដាក់អំណះអំណាងបែបនេះនៅពាក់កណ្តាលខែវិច្ឆិកា ដើម្បីកុំឲ្យមានការពន្យារពេលនៅក្នុងដំណើរនីតិវិធីដែលកំពុងតែបន្ត ។

---

១៤ និង មាត្រា ១៥ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និង នយោបាយ ឆ្នាំ១៩៦៦ ត្រូវតែគោរពនៅទូទាំងដំណើរជំនុំជម្រះសេចក្តី"។

00234907

D99/3/26



សូមអង្គបុរេជំនុំជម្រះទទួលយកសំណើរួមនេះដោយក្តីគោរព។

ធ្វើនៅភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២៣ ខែតុលា ឆ្នាំ ២០០៨

AVOCAT ATTORNEY AT LAW KINGDOM OF CAMBODIA

លោកស្រីមេធាវី ផាត់ ពៅស៊ាង

កញ្ញា Diana ELLIS QC

**សហមេធាវីអ្នកស្រី អៀង ធីរិទ្ធ**

លោក ស សូវ៉ាន

លោក Jacques VERGÈS

**សហមេធាវីលោក ខៀវ សំផន**

លោក សុន អរុណ

លោក Michiel PESTMAN

លោក Victor KOPPE

**សហមេធាវីលោក នួន ជា**